ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

លេខាធិការដ្ឋាន

លេខ ៣៥៧ ឧ.ក្រ.ច-២០០២

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

# លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

**ជម្រាបមក**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**លោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង**
**លោកព្រះរាជអាជ្ញាគ្រប់អយ្យការខេត្ត-ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការឃុំខ្លួនពិរុទ្ធជនលើសថេរវេលាកំណត់នៃច្បាប់ ។

លេខាធិការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សូមជម្រាបឯកឧត្តម អស់លោក លោកស្រី ក្រោយពីបានចុះទៅក្តាប់ស្ថានភាពការងារនៅគ្រប់តុលាការ និងមន្ទីរឃុំឃាំងទូទាំងព្រះរាជាណាចក្រកម្ពុជា ក្រុមការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានសង្កេតឃើញថាពិរុទ្ធជនមួយចំនួនធំពិសេសនៅរាជធានីភ្នំពេញត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នលើសថេរវេលាកំណត់នៃបញ្ញត្តិច្បាប់ពី៧ខែ ទៅ១ ឆ្នាំ ។

ការឃុំខ្លួនលើសថេរវេលានេះ មានកត្តាជាច្រើនដែលឆ្លើយដាក់គ្នារវាងតុលាការ និងប្រធានមន្ទីរឃុំឃាំងខ្លះថាមកពីតុលាការឃុំលើសដោយខ្លួនឯង ខ្លះថាមកពីពន្ធនាគារគ្មានមធ្យោបាយដឹកជញ្ជូនពិរុទ្ធជន មកសវនាការតាមការកំណត់របស់តុលាការ បណ្តាលអោយតុលាការលើកពេលសវនាការជំនុំជម្រះជាច្រើនលើកខ្លះថាលុះត្រាតែតុលាការផ្តល់ថ្លៃឈ្នួលដឹកជញ្ជូនពិរុទ្ធជនមកសវនាការ ទើបមន្ទីរឃុំឃាំងមានលទ្ធភាពដឹកជញ្ជូនតាមការកំណត់ ។ ម្យ៉ាងទៀតនៅខេត្តមួយចំនួន ការដឹកជញ្ជូនពិរុទ្ធជនមកសវនាការមានលក្ខណៈមិនសមរម្យខ្វះសុវត្ថិភាពប៉ះពាល់ដល់សិទ្ធិនិងកិត្តិយសបុគ្គលផង ។

ដើម្បីអោយមានដំណើរការល្អនូវបញ្ហាដូចពោលខាងលើ លេខាធិការ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សំណូមពរសុំឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាចាត់ឱ្យប្រធាននាយកដ្ឋានពន្ធនាគារ ប្រគល់ឱ្យគ្រប់មន្ទីរឃុំឃាំងពិរុទ្ធជននូវរថយន្តសមស្របសម្រាប់ដឹកពិរុទ្ធជនទាំងអស់នោះមកកាន់តុលាការតាមដីការបស់តុលាការ ។

-សុំអោយលោកព្រះរាជអាជ្ញានៃអយ្យការគ្រប់ខេត្ត-ក្រុង តាមដានយ៉ាងល្អិតល្អន់អំពីពិរុទ្ធជនដែលត្រូវឃុំខ្លួនជាបណ្តោះអាសន្ន ឬ អោយនៅក្រៅឃុំជាបណ្តោះអាសន្ន ដើម្បីឱ្យដំណើរការសវនាការជំនុំជម្រះប្រព្រឹត្តទៅដោយគ្មានភាពមិនប្រក្រតី ។

-មិនគប្បីឱ្យមានជាបន្តទៀតនូវការដឹកជញ្ជូនពិរុទ្ធជន មកសវនាការជំនុំជម្រះតាមម៉ូតូឌុបឬរ៉ឺម៉កម៉ូតូដែលជាការបំពានទៅលើជំពូកទី១ ចំនុចទី ៤៥ (១) នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសម្រាប់ការគ្រប់គ្រងអ្នកទោសអនុម័តដោយសន្និបាតអង្គការសហប្រជាជាតិលើកទី១ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការប្រព្រឹត្តលើអ្នកទោសដែលបានប្រារព្ធនៅទីក្រុងហ្សឺណែវឆ្នាំ១៩៥៥ ហើយនិងបានទទួលការយល់ព្រមអោយប្រើប្រាស់ ពីក្រុមប្រឹក្សាផ្នែកសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចលេខ៦៦៣C (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ ហើយនិងសេចក្តីសម្រេចលេខ ២០៧៦ (LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧ ដែលបានកំណត់ថា“ នៅពេល

ដឹកជញ្ជូនអ្នកទោសពីកន្លែងមួយទៅកន្លែងមួយទៀតនោះធ្វើយ៉ាងណា កុំឱ្យសាធារណៈជនឃើញច្រើនពេកហើយ វិធានការការពារសមស្របនានាត្រូវតែយកមកអនុវត្ត ដើម្បីការពារអ្នកទោសឱ្យផុតពីការត្មះតិះដៀលការលេចមុខជាសាធារណៈទោះជាតាមទ្រង់ទ្រាយបែបណាក៏ដោយ " ។

-ចំពោះលោកចៅក្រមស៊ើបអង្កេត ត្រូវយកចិត្តទុកដាក់ស៊ើបអង្កេតប្រមូលភស្តុតាងឱ្យបានមូលសព្វគ្រប់មុនរយៈពេលកំណត់នៃច្បាប់ ដើម្បីតំណាងអយ្យការមានលទ្ធភាពពិនិត្យ និងធ្វើដីកាសន្និដ្ឋានស្ថាពរជូនរឿងទៅជម្រះ ។

-ចៅក្រមជំនុំជម្រះ ត្រូវកំណត់ពេលសវនាការជំនុំជម្រះឱ្យបានត្រឹមត្រូវជៀសវាងការឃុំខ្លួនជាបណ្តោះអាសន្នលើសការកំណត់នៃច្បាប់ ។

-ចំពោះមន្ទីរឃុំឃាំង នៃគ្រប់ខេត្ត-ក្រុង គួរតែមានកន្លែងឃុំខ្លួនបណ្តោះអាសន្នសមរម្យដាច់ដោយឡែកពីពន្ធនាគារ ពីព្រោះពិរុទ្ធជន ឬជនល្មើស ពុំមែនជាទណ្ឌិតទេ ។

-សេចក្តីដូចជម្រាបខាងលើ សូមឯកឧត្តម អស់លោក លោកស្រី មេត្តាជ្រាប និងពិនិត្យលទ្ធភាពចាត់ការតាមការគួរ ។

សូម **ឯកឧត្តម អស់លោក លោកស្រី** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២

**វៀល មួន**

ចម្លងជូន

- ឯកឧត្តមអភិបាលខេត្ត-ក្រុង
- លោកស្នងការខេត្ត-ក្រុង
- លោកប្រធានមន្ទីរកែប្រែព្រៃសទី១ (ម១) និងទី២(ម២)
- លោកប្រធានមន្ទីរឃុំឃាំង ខេត្ត-ក្រុង

" ដើម្បីជ្រាប "

ឯកសារ